# មកដល់ទៀតហើយ!

ព្រៃឈើ ជាជំរកបស់មនុស្ស សត្វឥរិទ្ធាយ!!

ព្រៃឈើពណ៌បៃតង ជួយបន្សុទ្ធបរិយាកាស!!



យុវសិស្ស ប៉េក ខេម សាលាបឋមសិក្សាព្រៃក្មេង



សួនផ្កានៅសាលាបឋមសិក្សា ចំការស្លែង



កុមារា ប៊ុត ម៉េង ថ្នាក់ទី ៦ ខ

Sponsored by

USAID
FROM THE AMERICAN PEOPLE

Produced by

Mlup Baitong PO Box 2510. Phnom Penh 3. Cambodia.
Tel/Fax: ++855-23-214-409. Mobile: ++855-12-909-502. e-mail: mlup@online.com.kh



មលប់បៃតង MLUP BAITONG

# បរិស្ថានខ្ញុំ

ព្រឹត្តិបត្រ

ចេញផ្សាយប្រចាំត្រីមាស (លេខ១៦)   ឆ្នាំទី៤ ខែមករា_មីនា ឆ្នាំ២០០៥

# ព្រៃ សហគមន៍



កុមារី សឿង ធា ថ្នាក់ទី ៦ សាលាបឋមសិក្សាព្រៃក្មេង

ហាមលក់

# អារម្ភកថា

## សួស្តី!

ប្អូនៗសិស្សានុសិស្សទាំងអស់ជាទីមេត្រី! ពេលនេះបរិស្ថានខ្ញុំលេខ១៦បានមកជួបនឹងប្អូនៗទៀតហើយ ។

តើប្អូនៗសុខសប្បាយឬទេ?

ព្រឹត្តិបត្រ"បរិស្ថានខ្ញុំ"មានសេចក្តីរីករាយយ៉ាងខ្លាំងដែលបានមកជួបប្អូនៗ តាមពាក្យសន្យាបីខែម្តង ដោយមានការចូលរួមសរសេរជាអត្ថបទខ្លី សំណួរ កំណាព្យ ចំរៀង និងគូររូបភាពរបស់ លោកគ្រូ អ្នកគ្រូ និងប្អូនៗ ។ យើងជឿជាក់ថា ប្អូនៗនឹងសប្បាយរីករាយ ក្នុងការតាមដានខ្លឹមសារនានាក្នុងព្រឹត្តិបត្រនេះ ។

តែកុំភ្លេចណា! លេខក្រោយព្រឹត្តិបត្របរិស្ថានខ្ញុំ នឹងចេញអំពី "សត្វព្រៃ ក្នុងសហគមន៍" ដូច្នេះប្អូនៗត្រូវបន្តការចូលរួមធ្វើព្រឹត្តិបត្រលេខក្រោយៗទៀត ។

បរិស្ថានខ្ញុំ ស្នាដៃខ្ញុំ

សូមអរគុណ!



កុមារា សួន វិចិត្រ ថ្នាក់ទី ៦

## មាតិកា


| | | | |
|---|---|---|---|
| ១.អារម្ភកថា | ២ | ២.អត្ថបទខ្លី | ៣ |
| ៣.អត្ថបទស្វែងយល់ | ៤ | ៤.ល្បែងសិក្សា | ៥ |
| ៥.កំណាព្យ | ៦ | ៦.ចំរៀង | ៧ |
| ៧.រឿងខ្លី | ៨ | ៨.ពាក្យបណ្តៅ | ៩ |
| ៩.សំណួរត្រិះរិះ | ១០ | ១០.សំណួរចំលើយ | ១១ |




យុវសិស្ស ហឹម ធា ថ្នាក់ទី ៦ សាលាព្រៃក្មេង



# អត្ថបទខ្លី

## ព្រៃសហគមន៍

ព្រៃសហគមន៍ គឺសំដៅដល់ព្រៃធម្មជាតិ ឬព្រៃដែលសហគមន៍បានដាំ និងថែរក្សា គ្រប់គ្រង និងប្រើប្រាស់ព្រៃឈើនោះប្រកបដោយនិរន្តរភាព ក្រោមកិច្ចព្រមព្រៀងរវាងរដ្ឋបាលព្រៃឈើ និងសហគមន៍មូលដ្ឋាន ។ (ច្បាប់ស្តីពីព្រៃឈើ)

សហគមន៍ព្រៃឈើ គឺសំដៅដល់សហគមន៍ដែលស្ម័គ្រចិត្តប្រមូលផ្តុំជាក្រុមដោយព្រមព្រៀងគ្នា ដើម្បីធ្វើសកម្មភាពអភិវឌ្ឍ និងប្រើប្រាស់ធនធានព្រៃសហគមន៍ប្រកបដោយនិរន្តរភាព ។

ព្រៃសហគមន៍ ផ្តល់ប្រយោជន៍ជាច្រើនដូចជា: ការពារការហូរច្រោះ ទប់ស្កាត់ការកាប់រានដីព្រៃ ទីជំរកសត្វព្រៃ ខ្យល់បរិសុទ្ធ ទាក់ទាញទឹកភ្លៀង ផ្តល់ជីជាតិសំរាប់ដំណាំកសិកម្ម ឱសថបុរាណ អុសដុតសំរាប់ចំអិនអាហារ និងផ្តល់ជាគ្រឿងសំណង់ផ្សេងៗ សំរាប់បំពេញដល់សេចក្តីត្រូវការរបស់ប្រជាពលរដ្ឋក្នុងសហគមន៍នោះក្នុងពេលបច្ចុប្បន្ន និងពេលអនាគតទៀតផង ។

ដូចនេះយើងត្រូវជួយគ្នាការពារ និងថែរក្សាព្រៃឈើនៅក្នុងតំបន់ ស្រុកភូមិរបស់យើងអោយបានល្អ ដោយបង្កើតជាសហគមន៍ព្រៃឈើ ។

កុមារា នីម សារឿន និងយ៉ែម វឌ្ឍា ថ្នាក់ទី ៦ ក
សាលាបឋមសិក្សាព្រៃក្មេង



## អត្ថបទស្វែងយល់

# កុមារ និងព្រៃសហគមន៍

បច្ចុប្បន្ននេះព្រៃឈើនៅក្នុងប្រទេសកម្ពុជា បាននឹងកំពុងទទួលរងការ កាប់បំផ្លាញយ៉ាងខ្លាំងដែលនាំឱ្យនៅតំបន់មួយចំនួន ជួបប្រទះនូវគ្រោះរាំងស្ងួត និងខ្វះខាតនូវធនធានព្រៃឈើសំរាប់ប្រើប្រាស់ ។

ក្រៅពីប្រយោជន៍ផ្នែកបរិស្ថាន ព្រៃឈើបានជួយបង្កើនជីវភាពរស់នៅរបស់ប្រជាជនថែមទៀតផងតាមរយៈ ការទាញយកផល និងអនុផលព្រៃឈើសំរាប់ជីវភាពរស់នៅប្រចាំថ្ងៃ ។ ដើម្បីការពារផលប្រយោជន៍ទាំងនេះ យើងត្រូវរួមគ្នាការពារព្រៃឈើក្នុងសហគមន៍យើងដោយបង្កើតជាសហគមន៍ព្រៃឈើ ។ ការចូលរួមរបស់ប្រជាជនពិតជាមានសារៈសំខាន់ខ្លាំងណាស់ក្នុងការគ្រប់គ្រងព្រៃសហគមន៍ ។ ក្នុងនោះកុមារដើរតួនាទីយ៉ាងសំខាន់ក្នុងការជួយអភិវឌ្ឍន៍សហគមន៍ព្រៃឈើតាមរយៈ ការចូលរួមឃ្លាំមើល និងផ្តល់ដំណឹងអំពីការកាប់ឈើខុសច្បាប់នៅក្នុងព្រៃសហគមន៍ ចូលរួមការពារ និងការពារភ្លើងឆេះព្រៃ ព្រមទាំងជួយបង្កើនការយល់ដឹងពីព្រៃសហគមន៍ និងការដាំដើមឈើឡើងវិញ ។ ដូចនេះយើងជាកុមារត្រូវចូលរួមអភិវឌ្ឍន៍ព្រៃសហគមន៍ ។



យុវសិស្ស ស៊ឹម ស្រី ថ្នាក់ទី ៦ ក

សាលាបឋមសិក្សាព្រៃក្លូង

**"ព្រៃឈើ គឺជាជីវិតរបស់យើង"**



# ល្បែងគំនិតក្មេង

## សូមជួយថែរក្សា ការពារព្រៃឈើ និងសត្វព្រៃ!



# កំណាព្យ

## ប្រយោជន៍ព្រៃឈើ

### (បទព្រហ្មគីត)

និពន្ធដោយលោកគ្រូ ប្រាក់ វណ្ណា សាលាបឋមសិក្សា ម៉ឺងក្បេង

១-មនុស្សសត្វត្រូវពឹងព្រៃ
ព្រោះតែយើងបណ្តោយ


កុមារី ស៊ី សុគារ ថ្នាក់ទី ៦ក បឋមសិក្សាក្រពាំងឪឡិប

តែសព្វថ្ងៃព្រៃខ្សត់ខ្សោយ
កាប់វាហើយមិនដាំវិញ ។

២-ព្រៃជួយទាញទឹកភ្លៀង
ធ្វើស្រែបានចំណេញ

អាកាសទៀងភ្លៀងពាសពេញ
ផ្តល់ផលវិញហូបមិនខ្វះ ។

៣-ភូមិដ្ឋានស្រស់អស្ចារ្យ
ព្រៃមានប្រយោជន៍ណាស់


កុមារា ឆៃ ភ័ន់ណោត ថ្នាក់ទី ៦ខ សាលាបឋមសិក្សាក្រពាំងឪឡិប

ព្រោះព្រឹក្សាច្រើនស្ដេកស្គះ
ចូរក្មេងចាស់ចាំជានិច្ច ។


ថ្នាក់ទី៥ ក សាលាបឋមសិក្សាក្រពាំងឪឡិប

៤-ក្រៅពីផ្តល់អុសដុត
យើងមិនត្រូវបំភ្លេច

ផលឱសថក៏មិនតិច
ផលសំរេចមានក្រាស់ក្រៃ ។

៥-វាបានផ្តល់ជាម្លប់
រស់នៅគ្មានភិតភ័យ


កុមារី សាន សំបូរ ថ្នាក់ទី៥ ខ សាលាបឋមសិក្សាក្រពាំងឪឡិប

ទាំងថ្ងៃយប់សត្វលកលៃ
ដោយសារព្រៃសហគមន៍ ។

៦-ដូច្នេះយើងត្រូវចាំ
ការពារអោយវាធំ

ជួយថែដាំព្រៃក្បែរភ្នំ
ទើបសហគមន៍យើងជឿនលឿន ។



# ចំរៀងបរិស្ថាន

## ព្រឹក្សព្រៃសុគាំ


កុមារី ឆៃ សុខុម ថ្នាក់ទី៦

ច្រៀងដោយលោក ណាយ ភ័ន់ណោត

១- ឱម្លប់ត្រជាក់...ត្រឈើងត្រឈៃ
ឱ្យចិត្តចង្អៀត...ប្រែស្រលះថ្លា

ព្រឹក្សាលាស់ខ្ចី...នៃបុព្វតា
ដូចគាប់នេត្រា...ជិតជាប់នេសា

"បន្ទរ"....អឺយ....

២-សំលឹងព្រៃស្រោង...គោងមែកសាខា
ផ្កាក្ខុងទៅអ្នក...សំរួលកាយចិត្ត

មិនចង់ឃ្លាតឃ្លា...នៅនៃបនិត
ព្រះពាយផាយផាត់...ជិតជាប់នាសា

"បន្ទរ"...អឺយ...

៣-ព្រៃអើយព្រៃខ្ទង...ខ្ទងអើយខ្ទងត្បែង
ក្រញូងខាងខ្នង...ត្រាចល្វេចស្នេហា

កកោះស្ងប់ស្ងែង...ប្រឡែងត្រឹស្នា
ធ្នង់បេងអស្ចារ្យ...សង្ហាដូចចន្ទ័

"បន្ទរ"...អឺយ...

៤-ឈើអើយសូមអ្នក...គង់វង្សស្ថិតស្ថេរ
ឱ្យមនុស្សក្នុងលោក...អត់អ្នកមិនបាន

អ្នកជាម្ចាស់ស្នេហ៍...នៅគ្រប់ទិសស្ថាន
ផ្តល់ភាពសុខសាន្ត...មិនចេះឡើយណាយ

"បន្ទរ"...អឺយ...

៥-លើកហត្ថបួងសួង...សូមអស់ទេព្តា
អង្វរចិត្តមនុស្ស...ដែលនាំអន្តរាយ

ជួយថែរក្សា...ឈើព្រៃទាំងឡាយ
ឱ្យចិត្តប្រែក្លាយ...ស្រឡាញ់រក្សា

"បន្ទរ"...អឺយ...

**ទំព័រកំសាន្ត** **រឿងខ្លី**



# យើងនាំគ្នាការពារព្រៃក្នុងសហគមន៍

នៅពេលសំរាកមេរៀនលេង កុមារពីរនាក់ឧង្គុយនិយាយគ្នាលេងពីក្រោមដើមឈើនៅក្នុងសាលាគមន៍របស់ពួកគេ ។

**ស៊ីថា:** នែ! សុភា ព្រឹកនេះហាក់ដូចជាក្ដៅដល់ហើយ ។

**សុភា:** ស៊ីថា! មិនមែនតែព្រឹកនេះទេ គឺក្ដៅរាល់តែថ្ងៃហ្នឹង ។ ឪពុកខ្ញុំនិយាយថា មកពីភូមិយើងមិនសូវសំបូរព្រៃឈើបានជាវាក្ដៅអញ្ចឹង ។

**ស៊ីថា:** តើឯងដឹងថា ព្រៃឈើមានប្រយោជន៍ដូចម្ដេចខ្លះទៅ?

**សុភា:** ខ្ញុំឮចាស់ៗនិយាយថា វាអាចការពារការហូរច្រោះ ធ្វើអោយអាកាសធាតុត្រជាក់ និងខ្យល់បរិសុទ្ធ ទាក់ទាញទឹកភ្លៀង ធ្វើអោយដីមានជីជាតិ ផ្ដល់ឱសថបុរាណ គ្រឿងសំណង់ អុសដុត និងផ្ដល់នូវផលប្រយោជន៍ជាច្រើនទៀតណាស់ណាញ់!

**ស៊ីថា:** អញ្ចឹង! តើយើងត្រូវធ្វើដូចម្ដេចទៅ?

**សុភា:** យើងត្រូវជួយគ្នាថែរក្សាព្រៃឈើដែលនៅសល់ ដោយបង្កើតជាសហគមន៍ព្រៃឈើ និងនាំគ្នាដាំដើមឈើបន្ថែមទៀត ហើយបន្ថែមពីលើនេះយើងអាចជួយឃ្លាំមើល និងផ្ដល់ព័ត៌មានផ្សេងៗដែលទាក់ទងនឹងព្រៃសហគមន៍យើងដល់អ្នកភូមិទៀតផងណា ។

**ស៊ីថា:** អរគុណណាស់សំឡាញ់! ពេលនេះខ្ញុំបានយល់ច្បាស់ហើយពីសារៈប្រយោជន៍នៃព្រៃសហគមន៍ ។



# ពាក្យបណ្ដៅ

## ចំលើយ ពាក្យបណ្ដៅព្រឹត្តិបត្រលេខ១៥

១-ក្ដែក ២-ត្រីឆ្មារ សត្វឆ្មារ និងខ្សែឆ្មារ ៣-ត្រីអណ្ដាតឆ្កែ ៤-ព្រួល)

<u>សំនួរ:</u>

មានមើម មានផ្កា មានបន្លា គ្មានស្លឹក។ តើជាអ្វី?

ខ្ញុំជាសត្វស្វា លុបសក់កាលណាក្លាយជាដើមឈើ។ តើជាដើមអ្វី?

រុក្ខាមានឈ្មោះពីរម៉ាត់ ប្តូរពាក្យខាងដើមចាស់បាត់ ផ្លាស់ថ្មីជាក្សត្រ ក្លាយជាភោគ។ តើជាដើមអ្វី?

ខ្ញុំជារុក្ខា មានឈ្មោះពីរម៉ាត់ លុបខាងដើមបាត់ក្លាយជា ចី នៅកណ្ដាលទឹក។ តើជាដើមអ្វី?



កុមារា សេង ឿន ថ្នាក់ទី ៦ ក



កុមារា រឹម សុខា ថ្នាក់ទី ៥ ខ សាលាបឋមសិក្សាត្រពាំងឫស្សី

# សំណួរត្រិះរិះ

**សំនួរ១**-ដូចម្ដេចដែលហៅថា សហគមន៍ព្រៃឈើ?

**ចំលើយ**:........................................................................................................

........................................................................................................................

**សំនួរ២**-ចូរប្អូនៗសរសេរឈ្មោះរុក្ខជាតិក្នុងសហគមន៍របស់ប្អូនៗឱ្យបាន ៥ប្រភេទ?

**ចំលើយ**:........................................................................................................

........................................................................................................................

**សំនួរ៣**-តើព្រៃសហគមន៍មានសារៈប្រយោជន៍អ្វីខ្លះ?

**ចំលើយ**:........................................................................................................

........................................................................................................................

**សំនួរ៤**-តើកាប់បំផ្លាញព្រៃឈើបណ្ដាលឱ្យមានបញ្ហាអ្វីខ្លះកើតឡើង?

**ចំលើយ**:........................................................................................................

........................................................................................................................

**សំនួរ៥**-ដើម្បីថែរក្សាព្រៃឈើឱ្យបានគង់វង្ស តើប្អូនៗត្រូវធ្វើដូចម្ដេចខ្លះ?

**ចំលើយ**:........................................................................................................

........................................................................................................................



# សំនួរ -ចំលើយ

១ - ដូចម្ដេចដែលហៅថា ព្រៃសហគមន៍?

(កុមារ សួន ធន់ សាលាបឋមសិក្សាបន្ទាប់)

**ចំលើយ:** (សូមមើលនៅទំព័រទី៣ "អត្ថបទខ្លី")

២ - ដើម្បីថែរក្សាការពារព្រៃសហគមន៍ តើយើងត្រូវធ្វើដូចម្ដេច?

(កុមារ ជួប លីនណា ថ្នាក់ទី ៦ សាលាបឋមសិក្សាបន្ទាប់)

**ចំលើយ:** ដើម្បីថែរក្សាការពារព្រៃសហគមន៍ យើងត្រូវនាំគ្នាដាំដើមឈើឡើងវិញ ផ្សព្វផ្សាយដល់អ្នកនៅក្បែរខាងគ្នាឱ្យយល់ដឹងអំពី ផលប្រយោជន៍ព្រៃសហគមន៍ និងរួមគ្នាបង្កើតជាសហគមន៍ព្រៃឈើ ។

៣ - តើព្រៃសហគមន៍មានប្រយោជន៍អ្វីខ្លះ?

(កុមារ ពិន សេរី)

**ចំលើយ:** ព្រៃសហគមន៍មានផលប្រយោជន៍ជាច្រើនដូចជា: ជាទីជំរករបស់សត្វ មានខ្យល់បរិសុទ្ធ ជួយទាញទឹកភ្លៀង ផ្ដល់ជីជាតិ ដល់ដំណាំកសិកម្ម មានបរិស្ថានល្អ ជាឱសថ និងសំរាប់បំពេញសេចក្ដីត្រូវការរបស់មនុស្ស ទាំងពេលបច្ចុប្បន្ន និងអនាគត ។

កុមារា ហៃម ហុម ថ្នាក់ទី ៦ក

